ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្ដីណែនាំ

# ស្ដីពី

# ការអនុវត្តបទបញ្ជាលេខ០១ បប ចុះ ថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១២ របស់រាជរដ្ឋាភិបាល ស្ដីពីការពង្រឹង និងបង្កើតប្រសិទ្ធិភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ចពាក់ព័ន្ធនឹងតំបន់សហគមន៍ជនជាតិដើមភាគតិច

# ឆ្នាំ ២០១២

បណ្ណាល័យច្បាប់-Law Library
(lawlibrarysite.wordpress.com)

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ**
**ក្រុមប្រឹក្សាគោលនយោបាយដីធ្លី**
លេខ ០៤៧០......សណន/កគដ

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ ២០១២

# សេចក្តីណែនាំ

**ស្តីពីការអនុវត្តបទបញ្ជាលេខ០១ បប ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១២**
**របស់រាជរដ្ឋាភិបាលស្តីពីការពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច**
**ពាក់ព័ន្ធនឹងតំបន់សហគមន៍ជនជាតិដើមភាគតិច**

ដើម្បីអនុវត្តបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ០១បប ស្តីពីវិធានការពង្រឹងនិងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច និងលើកកម្ពស់សុវត្ថិភាពនៃការកាន់កាប់ដីធ្លីក្នុងតំបន់ដែលមានជនជាតិដើមភាគតិចរស់នៅ និងដោយយុទ្ធនាការអនុវត្តនយោបាយចាស់សកម្មភាពថ្មីលើវិស័យដីធ្លីមានរយៈពេលកំណត់និងស្ថិតក្នុងគំរោងថវិកាឆ្នាំ២០១២ប៉ុណ្ណោះ ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី សូមធ្វើការណែនាំអំពីការអនុវត្តបន្ថែមពីលើឯកសារដែលមានជាធរមានដល់ប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋគ្រប់ខេត្ត ទាក់ទងនឹងដីរបស់សហគមន៍ជនជាតិដើមភាគតិច ដូចតទៅ៖

- ដោយការកំណត់ព្រំប្រទល់ក្បាលដីទាំងឡាយជាកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ជាពិសេសដីចម្ការវិលជុំដែលជាចំណែកដីសាធារណៈរបស់រដ្ឋ មានច្រើនកន្លែងនៅរាយប៉ាយ ត្រូវការពេលវេលាយូរ និងចំណាយថវិកាច្រើន ការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ត្រូវទុកអនុវត្តនៅពេលក្រោយ តាមស្មារតីនៃអនុក្រឹត្យលេខ ៨៣ អនក្រ.បក ចុះថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ២០០៩។
- **ចំពោះជនជាតិដើមភាគតិចដែលមិនចូលជាសមាជិកសហគមន៍ ហើយចង់រស់នៅជាឯកជន** ត្រូវអនុវត្តដូចមានចែងក្នុងសេចក្តីណែនាំលេខ០១៥ សណនជនស/កគដ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១២ ត្រង់ចំណុច ៣។ បន្ថែមលើសេចក្តីណែនាំនេះ ចាំបាច់ត្រូវមានកិច្ចសន្យាស្ម័គ្រចិត្តចង់រស់នៅជាឯកជន ដោយមានផ្តិតស្នាមមេដៃរបស់សាម៉ីជនទុកជាភស្តុតាងទៅថ្ងៃក្រោយ។

សេចក្តីណែនាំនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី**

**អ៊ឹម ឈុនលឹម**

*ចម្លងជូន៖*
- *ក្រសួង/ស្ថាប័នជាសមាជិកក្រុមប្រឹក្សាគោលនយោបាយដីធ្លី*
- *ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
  *"ដើម្បីជូនជ្រាប"*
- *គ្រប់រាជធានី ខេត្ត*
- *គ្រប់អគ្គនាយកដ្ឋាន និងអង្គភាពជុំវិញក្រសួង ដ.ន.ស.*
- *គ្រប់មន្ទីរ ដនសស រាជធានី ខេត្ត*
  *"ដើម្បីអនុវត្ត"*
- *ឯកសារ កាលប្បវត្តិ*